# ភ្លេច ការហួសចិត្ត និងការសម្រាកទៅបន្ទប់ទឹក

**ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១១**

**ដោយ គ្រីសស៊ី អ៊ីវេន**

*ប្រែសម្រួលដោយ ដា ដល្លា*

ការពន្យារពេល និងផលលំបាកដែលកើតមានក្នុងអំឡុងពេលនៃដំណើរការលើករណី០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តរហូតដល់ថ្ងៃទីបីទៀត នៃសវនការលើភស្តុតាងនេះ ដែលមើលទៅការពន្យារពេល និងផលលំបាកនោះនឹងគ្មានទីបញ្ចប់ទេ ។ នៅអំឡុងពេលនៃដំណើរការសវនាការកាលពីម្សិលមិញ តុលាការបានដោះស្រាយបញ្ហាជាច្រើនតាំងពីបញ្ហាសុខភាពរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ និងបញ្ហាភ្លេងបុណ្យសពដែលជាការបង្អាក់ដល់ដំណើរការប្រព័ន្ធវីដេអូ ជាមួយនិងសាក្សីទីមួយរបស់ព្រះរាជអាជ្ញា ។ ភាពតានតឹង និងកិច្ចដំណើរការរអាក់រអួលដែលកើតឡើងក្នុងអំឡុងពេលនៃកិច្ចដំណើរការនេះកើតមានតាំងពីសវនាការនេះចាប់ផ្តើមពីរសប្តាហ៍មុនមកម្ល៉េះ ហើយគ្មានសញ្ញាណាមួយស្រាកស្រាន្តឡើយ ។

## កម្មវិធីមានការផ្លាស់ប្តូរទៀត

ព្រឹកនេះ ចៅក្រមបានមកដល់ក្នុងបន្ទប់សវនាការយឺត១៥នាទី ។ ក្រោយពីបន្តាប់ឲ្យចាប់ផ្តើមដំណើរការភ្លាម ចៅក្រម និល ណុន បានជម្រាបនូវអ្វីដែលចៅក្រមមកយឺត ហើយចៅក្រមបានជូនដំណឹងទៅគ្រប់ភាគីទាំងអស់ថា ថ្ងៃនេះមានការប្រែប្រួលកម្មវិធីមួយចំនួន ។ ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន ហ៊ីត ដែលរំពឹងថានឹងមកបន្តធ្វើសក្ខីកម្មនៅថ្ងៃនេះ មិនអាចចូលមកក្នុងបន្ទប់សវនាការបានទេ ដោយសារតែបញ្ហាសុខភាព ហើយតុលាការត្រូវបង្ខំចិត្តពន្យារពេល និងរៀបចំពេលវេលាដើម្បីឲ្យ ក្លាន ហ៊ីត ចូលមកធ្វើសក្ខីកម្មនៅពេលក្រោយវិញ ។

តុលាការបានរៀបចំឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីទីពីរ ដែលគ្រោងនឹងចូលមកធ្វើសក្ខីកម្ម នាដំណាក់កាលដំបូងនេះចូលធ្វើសក្ខីកម្មព្រឹកនេះ ។ ចៅក្រម និល ណុន បានរាយការណ៍ថា តុលាការបានដំឡើង ប្រព័ន្ធវីដេអូដែលបានជម្រាបកាលពីម្សិលមិញរួចហើយ នៅកន្លែងមួយដែលសាក្សី TCW ៣៩៥ របស់ព្រះរាជអាជ្ញារស់នៅ ហើយថា សាក្សីមានសុខភាពល្អគ្រាន់បើនៅថ្ងៃនេះ ។ តុលាការបានរៀបចំកម្មវិធី ដើម្បីឲ្យសាក្សីរូបនេះឆ្លើយសំណួរនៅពេលរសៀលនេះ ហើយតុលាការបានរុញពេលឲ្យ នួន ជា និយាយទៅថ្ងៃពេលក្រោយវិញដោយមិនកំណត់ឡើយ ។

## បញ្ហាបឋមមួយចំនួន

ចៅក្រម និល ណុន បានអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីទីពីរឈ្មោះ រម៉ាំ យុន ចូលក្នុងទីកន្លែងសម្រាប់សាក្សីដើម្បីធ្វើសក្ខីកម្ម ។ នៅពេលដែល រម៉ាំ យុន ត្រូវបាននាំចូលទៅក្នុងកន្លែងសម្រាប់សាក្សីធ្វើសក្ខីកម្ម ម៉ៃ ឃើល ខណាវ៉ាស មេធាវីរបស់ជនជាប់ចោទ អៀង សារី បានស្នើសុំទៅតុលាការដោយរាយការណ៍ថា ក្រោយពីសវនាការបញ្ចប់កិច្ចដំណើរការកាលពីម្សិលមិញ ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្វាន ហ៊ីត “ចាប់ផ្តើមប្រឡាក់ប្រឡូកជាមួយអ្នកផ្សេង” ហើយអ្នកផ្សេងនេះ “កំពុងតែអរកញ្ជ្រៀវ និងកំពុងតែអង្អែលខ្នងគាត់” ។ មេធាវី ខណាវ៉ាស បានអះអាងថា តុលាការគួរតែបង្កើតការអនុវត្តបទដ្ឋានមួយជាមួយនឹងសាក្សី ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដោយមិនឲ្យទាក់ទងជាមួយសាក្សី ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត រហូតដល់អ្នកទាំងនោះធ្វើសក្ខីកម្មរួចហើយ ។

ចៅក្រម និល ណុន បានឆ្លើយតបថា តុលាការបានជម្រាបដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីរួចហើយអំពីបញ្ហានេះ ហើយបានសហការជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញរួចហើយ ដើម្បីធានាថា អ្នកដែលត្រូវចូលមកធ្វើសក្ខីកម្មមិនអាចជួបគ្នាបានទេ ។ ដោយបញ្ជាក់ឡើងវិញថា ករណីនេះមានភាពស្មុគស្មាញច្រើន ចៅក្រម និល ណុន បានបញ្ជាក់ថា ពេលខ្លះតុលាការមិនអាចគ្រប់គ្រងរាល់សកម្មភាពបានទេ តែគាត់ស្នើសុំថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញត្រូវធ្វើកិច្ចការបន្តទៀតដើម្បីសម្រេចកិច្ចការទាំងនេះ ។ សហព្រះរាជអាជ្ញាបានយកឱកាសដែលតុលាការស្ងប់ស្ងាត់បន្តិចនេះ ដើម្បីជម្រាបទៅតុលាការថា សហព្រះរាជអាជ្ញាចង់ធ្វើការសាកសួរសាក្សីដែលនឹងចូលមកធ្វើសក្ខីកម្មនៅពេលរសៀលនេះ ទាក់ទងទៅនឹងអង្គហេតុអំពីការជាប់បទពិរុទ្ធ ជាជាងសួរនាំអំពីបញ្ហាមួយចំនួនដែលត្រូវបានចាត់តាំងឲ្យសួរនាំដំណាក់កាលដំបូង ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា សំណើនេះធ្វើឡើងដោយផ្អែកទៅលើ “ហេតុផលខុសពីធម្មតា” នៃស្ថានភាពសុខភាពរបស់សាក្សី ។ ដូចដែលអង្គជំនុំជម្រះបញ្ជាក់កាលពីដំបូងរួចហើយ ស្ថានភាពសុខភាពរបស់សាក្សីមានសភាពកាន់តែធ្ងន់ឡើងៗ ។

មេធាវី ខណាវ៉ាស បានជំទាស់ទៅនឹងសំណើនោះ ដោយបញ្ជាក់ថា សំណើទាំងនោះត្រូវតែរៀបចំឲ្យបានល្អជាលាយលក្ខណ៍អក្សរជាមុន ហើយផ្ញើទៅតុលាការផ្ទាល់ មិនមែនស្នើជាសាធារណៈបែបនេះទេ ហើយត្រូវអនុញ្ញាតឲ្យភាគីផ្សេងទៀតឆ្លើយតបបានផង ។ ដោយចោទប្រកាន់សហព្រះរាជអាជ្ញាថា “កំពុងបញ្ចុះបញ្ចូលសាធារណជន” មេធាវី ខណាវ៉ាស បានប្រកាសថា គាត់មានអារម្មណ៍ថា ត្រូវបាន“បំផ្លាញនិងវាយឆ្នក់”ជាមួយនឹងសំណើដែលធ្វើឡើងភ្លាមៗបែបនេះ ។ មេធាវី ខណាវ៉ាស បានសន្និដ្ឋានថា “យើងគួរតែនិយាយពីសវនាការភ័ស្តុតាង មិនមែនបញ្ហានីតិវិធីទាំងនេះទេ” ។

ចៅក្រម និល ណុន បានបញ្ឈប់ការប្រកែកគ្នានេះភ្លាមដោយបញ្ជាក់ថា «យើងមិនគួរបន្តជជែកគ្នាបែបនេះទៀតទេ» ហើយចៅក្រមក៏បានងាកមកមើលភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលកំពុងអង្គុយនៅទីកន្លែងសម្រាប់សាក្សីដើម្បីធ្វើសក្ខីកម្ម ។

## ភាគីដើមបណ្តឹងរដ្ឋប្បវេណីចូលធ្វើសក្ខីកម្ម

សក្ខីកម្មរបស់ រម៉ាំ យុន អាយុ៧០ឆ្នាំ ធ្វើឡើងតែមួយព្រឹកប៉ុណ្ណោះ ។ ការសួរសំណួរទៅកាន់ភាគីដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ធ្វើឡើងដោយយឺតៗដោយសារតែ រម៉ាំ យុន មានការភាន់ច្រឡំអំពីសំណួរមួយចំនួន ហើយគាត់បានពិគ្រោះជាមួយអ្នកប្រែសម្រួលភាសាដែលអង្គុយនៅជិតគាត់ជាញឹកញាប់ ។ ទោះបីជាអ្នកបកប្រែភាសាខ្មែរ-អង់គ្លេសរបស់តុលាការព្យាយាមបកប្រែសម្តីរបស់ រម៉ាំ យុន រហូតក៏ដោយ ក៏អ្នកតាមដានដែលជាជនជាតិខ្មែរកត់សម្គាល់ឃើញថា ចម្លើយរបស់ រម៉ាំ យុន គឺមិនត្រឹមត្រូវ ហើយជាញឹកញាប់មិនឆ្លើយតបទៅនឹងសំណួរដែលបានសួរមកគាត់ទេ ។ ខណៈពេលដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាបញ្ចប់ការសួរដេញដោលហើយនោះ វានៅតែមិនទាន់ដឹងច្បាស់នៅឡើយថា តើចម្លើយដែលឆ្លើយនោះ អាចទទួលយកបានកម្រិតណាទៅចំពោះមុខតុលាការ ។

សក្ខីកម្មរបស់ រម៉ាំ យុន ចាប់ផ្តើមដោយការសួរអំពីប្រវត្តិរូបសង្ខេបដែលសួរដោយចៅក្រម និល ណុន ។ រម៉ាំ យុន បាននិយាយថា គាត់កើតនៅភូមិតូចមួយនៅភាគឦសាន ហើយគាត់បន្តរស់នៅទីនោះរហូតដល់សព្វថ្ងៃនេះដោយប្រកបរបរកសិកម្ម ។ គាត់និងប្រពន្ធរបស់គាត់មានកូនបួននាក់ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីចាប់ផ្តើមសួរអំពីស្ថានភាពរបស់ រម៉ាំ យុន មុនឆ្នាំ១៩៧៥ ។ រម៉ាំ យុន បានឆ្លើយទៅតុលាការអំពីអារម្មណ៍របស់គាត់ចំពោះគោលនយោបាយនិងសកម្មភាពរបស់ខ្មែរក្រហម ដោយបញ្ជាក់ថា «ខ្ញុំមិនដឹងថាធ្វើការជាមួយខ្មែរក្រហមត្រូវឬខុសទេ តែគោលនយោបាយបក្សរបស់ខ្មែរក្រហមមិនត្រឹមត្រូវទេ ។ ខ្មែរក្រហមមានភាពជ្រុលហួសហេតុពេក ហើយរំលោភសិទ្ធិមនុស្សទៀត ។ ខ្មែរក្រហមបង្ខំឲ្យមនុស្សធ្វើការហួសហេតុ ។ បើយើងមិនធ្វើការ យើងទាំងអស់គ្នាអត់មានអីហូបទេ ។ មាគ៌ានយោបាយនោះផ្តាច់ការខ្លាំងណាស់» ។ ដោយប្រៀបធៀបខ្មែរក្រហមទៅនឹងឪពុកម្តាយវិញ រម៉ាំ យុន បាននិយាយថា «ខ្មែរក្រហមគួរតែអប់រំយើង និងថែទាំយើងឲ្យបានល្អ តែខ្មែរក្រហមបែរជាដាក់គុកយើងទៅវិញ» ។

មុននឹង រម៉ាំ យុន ចាប់និយាយបន្តទៀត ចៅក្រម និល ណុន បាននិយាយកាត់ ហើយបានប្រាប់គាត់ឲ្យផ្ទៀងស្តាប់សំណួរឲ្យបានច្បាស់សិនមុននឹងឆ្លើយ ។ ចៅក្រមបានប្រាប់ទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីឲ្យសម្រួលសំណួរឲ្យខ្លីនិងច្បាស់ ហើយចម្រាញ់រកចម្លើយដែលសមស្របប៉ុណ្ណោះ ។ ក្រោយ

មក រម៉ាំ យុន អាចឆ្លើយសំណួរដែលសួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទោះបីជាមេធាវីនោះមិនពេញចិត្តនឹងសំណួរដ៏ខ្លីរបស់ខ្លួនក៏ដោយ ។ រម៉ាំ យុន បានរៀបរាប់ថា "កាលពីរបប ប៉ុល ពត ដំបូង" មុនឆ្នាំ១៩៧៥ គាត់ធ្វើជានិរសារនាំសំបុត្រទៅកម្មាភិបាលធំៗ ។ គាត់បានយកសំបុត្រពីភូមិមួយទៅភូមិមួយ ទៅឲ្យកម្មាភិបាលនៅក្នុងឃុំ ។ ជួនកាល គាត់ធ្វើដំណើររហូតដល់ព្រំដែនកម្ពុជា-វៀតណាម ដើម្បីនាំសំបុត្រទាំងនេះ ។ រម៉ាំ យុន បានរៀបរាប់ទៀតថា គាត់ធ្លាប់យកសំបុត្រទៅឲ្យ វ៉ាន់ នៅភូមិភាគឦសាន ។ នៅពេលសួរថាតើឈ្មោះ វ៉ាន់ មានឈ្មោះអ្វីទៀតដែរឬទេ? រម៉ាំ យុន បានឆ្លើយថា "ខ្ញុំដឹងតែ វ៉ាន់ ប៉ុណ្ណោះ តែក្រោយមកទើបដឹងថា វ៉ាន់ មានឈ្មោះផ្សេងទៀត" (វ៉ាន់ គឺ អៀង សារី) ។ រម៉ាំ យុន បញ្ជាក់ទៀតថា គាត់មិនដឹងពីខ្លឹមសារនៅក្នុងសំបុត្រដែលគាត់បញ្ជូនទៅ វ៉ាន់ ទេ ព្រោះសំបុត្រនោះសម្ងាត់ណាស់ ហើយ "ខ្ញុំក៏គ្មានសិទ្ធិដឹងដែរ" ។

គាត់ធ្លាប់ធ្វើជាប្រធានភូមិដោយមានតួនាទីចាត់ចែងកិច្ចការស្រែចម្ការនៅក្នុងភូមិ ដោះស្រាយជីវភាពប្រជាជន និងលើកកម្ពស់ "សាមគ្គីភាព" ក្នុងបណ្តាប្រជាជននៅក្នុងភូមិ ។ ដោយសារតែគាត់មានសមត្ថភាពចាត់ចែងការងារក្នុងភូមិបានល្អ រម៉ាំ យុន ត្រូវបានដំឡើងទៅជាមេឃុំបន្តទៀត ដោយមើលការខុសត្រូវនៅក្នុងភូមិនិងឃុំទាំងមូល ។ ការងាររបស់គាត់មួយទៀតត្រូវ "បោសសម្អាត" ភូមិឃុំ និងកម្ចាត់អ្នកដែលមានសមាសភាព "អាក្រក់" ។ (ក្រោយមកនៅពេលសួរអំពីអត្ថន័យនៃពាក្យ "បោសសម្អាត" រម៉ាំ យុន បានឆ្លើយថា ពាក្យនេះមានន័យថា បោសសម្អាតស្មៅនៅក្នុងភូមិ) ។

នៅពេលដែលគាត់ធ្វើជាកម្មាភិបាលខ្មែរក្រហម រម៉ាំ យុន ត្រូវបានហៅទៅប្រជុំជាញឹកញាប់ ដែលការប្រជុំនោះរៀបរាប់ពីការធ្វើកសិកម្ម "សីលធម៌សមរម្យ" និងផែនការសម្រាប់ឃុំ ។ កិច្ចប្រជុំនោះ ត្រូវបានដឹកនាំដោយ វ៉ាន់ ។ នៅពេលសួរថាតើ វ៉ាន់ ជានរណា រម៉ាំ យុន បានឆ្លើយថា "វ៉ាន់ គឺជាជនជាតិខ្មែរ តែរូបរាងរបស់គាត់ដូចបារាំងអ៊ីចឹង" ។

នៅពេលសួរពីលទ្ធផលនៃការមិនសម្រេចផែនការដែលដាក់ជូនដោយមេដឹកនាំខ្មែរក្រហម រម៉ាំ យុន បានឆ្លើយថា អ្នកដែលមិនអាចសម្រេចផែនការនឹង "រាយការណ៍ឬយកទៅរៀនសូត្រ" ។ ជួនកាល អ្នកទាំងនេះត្រូវបានយកទៅដាក់គុក ឬឃុំឃាំង និងចោទថាខ្មាំងប្រឆាំងបដិវត្តន៍ ហើយជួនកាលយកអ្នកទាំងនោះទៅព្រៃដែលមានន័យថា សម្លាប់ចោល ។

នៅពេលសួរថា តើគាត់មានពាក្យចុងក្រោយអ្វីប្រាប់ទៅតុលាការទេ រម៉ាំ យុន បានបញ្ចប់ការធ្វើសក្ខីកម្ម ដោយធ្វើការសរុបសេចក្តីអំពីអារម្មណ៍ដែលមានចំពោះខ្មែរក្រហម ។ គាត់និយាយថា "ពេលខ្ញុំចូលបដិវត្តន៍ដំបូង យើងបង្កបង្កើនផល និងដាំដំណាំលូតលាស់បានល្អណាស់ តែលទ្ធផល គឺ

គ្មានបានអ្វីទាំងអស់ ។ ខ្មែរក្រហមមានគោលនយោបាយល្អ តែមិនបានធ្វើល្អជាមួយប្រជាជនទេ ។ ដើមឈើល្អ តែមិនមានផ្លែ» ។

ក្រោយពីមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសួរចប់ ពេជ អង្គ បានស្នើទៅថា តុលាការគួរតែទុកពេលឲ្យសាក្សីសម្រាកប្រាំនាទីមុននឹងសួរបន្តទៀតដោយសារតែ រម៉ាំ យុន មានការហត់នឿយ ព្រោះគាត់ ត្រូវបានសួរនាំច្រើនណាស់មកហើយកាលពីម្សិលមិញ ។ ក្រោយមក សវនាការសម្រេចថា ដល់ពេលសម្រាកនៅពេលព្រឹក ។

## ការឲ្យនិយមន័យទៅលើដែនកំណត់នៃសិទ្ធិរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីត្រឡប់ពីសម្រាកភ្លាម មេធាវី ខាណាវ៉ាស បានក្រោកឈរដើម្បីធ្វើការជំទាស់បន្ថែមទៅនឹងការតវ៉ារបស់គាត់កាលពីលើកមុន ។ មេធាវី ខាណាវ៉ាស បានបញ្ជាក់ថា គាត់បានកត់សម្គាល់ឃើញថា រម៉ាំ យុន និយាយជាមួយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីអំឡុងពេលសម្រាក ។ ដោយបញ្ជាក់ថា ទង្វើបែបនេះមិនត្រូវបានអនុញ្ញាតនៅក្នុងតុលាការទេ មេធាវី ខាណាវ៉ាស បានអះអាងថា ភាគីដើមបណ្ដឹងរដ្ឋប្បវេណីគួរចៀសវាងប្រឹក្សាជាមួយមេធាវីរបស់ខ្លួននៅក្នុងតុលាការ ព្រោះអាចជះឥទ្ធិពលដល់ការធ្វើសក្ខីកម្ម ។

សហព្រះរាជអាជ្ញារង វីលៀម ស្មីត បានឆ្លើយតបថា ព្រះរាជអាជ្ញាយល់ស្របជាមួយនឹងមេធាវីការពារក្ដី ។ នៅពេលដែលសាក្សីកំពុងតែផ្ដល់ភ័ស្ដុតាង សាក្សីមិនត្រូវជួបជាមួយនឹងមេធាវីទេ ។ តែ វីលៀម ស្មីត ក៏បានអះអាងដែរថា បទដ្ឋានដូចគ្នានេះគួរតែធ្វើឡើងចំពោះជនជាប់ចោទដែរ ត្រង់ថា មិនគួរឲ្យមានការពិភាក្សាគ្នាជាមួយមេធាវី និងជនជាប់ចោទដែលត្រូវមកធ្វើសក្ខីកម្មទេ ។

សហមេធាវីអន្តរជាតិនាំមុខ អេលីហ្សាប៊ែត ស៊ីម៉ូណូ ហូត បានឆ្លើយតបថា ភាគីដើមបណ្ដឹងរដ្ឋប្បវេណីមិនមែនជាសាក្សីទេ ដូច្នេះមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីគួរតែអនុញ្ញាតឲ្យពិគ្រោះជាមួយកូនក្ដីរបស់ខ្លួនបាន ។ ដោយអះអាងថា នេះគឺជាច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អេលីហ្សាប៊ែត ស៊ីម៉ូណូ ហូត បាននិយាយថា «ខ្ញុំមិនគិតថា យើងគួរតែយករឿងនេះមកនិយាយរាល់ថ្ងៃនោះទេ» ។

ដោយអះអាងថា គាត់មិនមែនចង់សំដៅថា មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែបង្ហាត់សាក្សីទេ នោះ មេធាវី ខាណាវ៉ាស បានអះអាងបន្ថែមទៀតថា ការអនុញ្ញាតឲ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីពិគ្រោះជាមួយមេធាវីរបស់ខ្លួនពេលដែលកំពុងធ្វើសក្ខីកម្មនេះ «ផ្ដល់ជាសញ្ញាថា ភាពមិនត្រឹមត្រូវកំពុងតែកើតឡើងហើយ» ។ មេធាវី ខាណាវ៉ាស បានរក្សាជំហរថា ពេលនេះតុលាការគួរតែហាមឃាត់ ដោយមិនឲ្យមានការផ្ដល់ប្រឹក្សាចំពោះភាគីទាំងអស់ ។ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាតិ

នាំមុខ ពេជ អន្ត បានបន្តសេចក្តីអះអាងបន្ថែមទៀត ដោយបញ្ជាក់ថា ច្បាប់ណាមួយដែលហាមឃាត់មិនឲ្យមេធាវីពិគ្រោះ ជាមួយដើមបណ្តឹងរដ្ឋប្បវេណីគឺ «ជាសកម្មភាពរើសអើងប្រឆាំងនឹងកូនក្តីរបស់យើង» ហើយភាពស្មើភាពចំពោះមុខច្បាប់ត្រូវបានរំលោភ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិម្នាក់បានរក្សាជំហរថា ការហាមឃាត់ដើមបណ្តឹងរដ្ឋប្បវេណីមិនឲ្យប្រឹក្សាជាមួយមេធាវី «គឺជាការប្រឆាំងនឹងច្បាប់ជាតិទាំងស្រុង» ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិការពារផលប្រយោជន៍របស់ខ្លួន ដូច្នេះទំនាក់ទំនងរវាងមេធាវី និងកូនក្តីរបស់ខ្លួនគួរតែធ្វើបានដូចគ្នាទៅនឹងជនជាប់ចោទ និងមេធាវីរបស់ខ្លួនដែរ ។

ចៅក្រម និល ណុន បានបញ្ចប់ការជជែកគ្នានេះ ហើយបកស្រាយថា តាមច្បាប់ជាតិ និងតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ ភាគីដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីមួយនៃដំណើរការសវនាការនេះ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្រឹក្សាជាមួយមេធាវីរបស់ខ្លួនបានគ្រប់កាលៈទេសៈទាំងអស់នៃដំណើរការសវនាការនេះ ។ ដោយអានវិធានផ្ទៃក្នុងលេខ៨៨ស្ទួនពីរ ចៅក្រម និល ណុន បានចង្អុលបង្ហាញថា វិធាននេះច្បាស់ណាស់ គឺចង់សំដៅទៅលើជនជាប់ចោទ សាក្សី និងអ្នកជំនាញ មិនមែនភាគីដើមបណ្តឹងរដ្ឋប្បវេណីទេ ហេតុដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្រឹក្សាជាមួយមេធាវីរបស់ខ្លួនគ្រប់ពេលទាំងអស់ ។

ក្រោយមក ចៅក្រម និល ណុន បានណែនាំទៅគ្រប់ភាគីទាំងអស់ថា តុលាការ និងសាក្សី TCW៣៩៥របស់ព្រះរាជអាជ្ញា នឹងធ្វើសក្ខីកម្មតាមប្រព័ន្ធវីដេអូនៅពេលរសៀលនេះ និងនៅថ្ងៃស្អែកបន្តទៀត ។ យោងតាមសុខភាព និងភាពចាស់ជរារបស់សាក្សី ចៅក្រម និល ណុន បានជម្រាបទៅមេធាវីថា មេធាវីអាចដាក់ជាសំណួរអំពីអង្គហេតុដែលផ្តល់និយមន័យរួចហើយ ទោះបីជាចៅក្រមមិនបានបញ្ជាក់ឲ្យច្បាស់ពីអង្គហេតុនេះមានន័យដូចម្តេចក៏ដោយ ។ ចៅក្រមក៏បានស្នើទៅភាគីទាំងអស់ឲ្យជូនដំណឹងមកតុលាការភ្លាម បើសិនជាសាក្សីណាមួយមានបញ្ហាសុខភាព ដូច្នេះភាគីទាំងអស់អាចត្រូវជូនដំណឹង និងត្រៀមខ្លួនឲ្យបានប្រសើរមុននឹងធ្វើសក្ខីកម្ម ។

## ការចោទសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីទីពីរបន្តទៀត

ចៅក្រម និល ណុន បានផ្តល់សិទ្ធិទៅសហព្រះរាជអាជ្ញា ដោយជូនដំណឹងថា មានពេលត្រឹមតែ៣០នាទីប៉ុណ្ណោះដើម្បីសួរ ។ សហព្រះរាជអាជ្ញាបានឆ្លើយតបដោយស្នើទៅតុលាការថា តុលាការគួរតែសម្របទៅតាមពេលវេលា ដោយសារតែភាគីដើមបណ្តឹងរដ្ឋប្បវេណីមានបញ្ហាខាងសុខភាពផង និងពិបាកយល់សំណួរផង ដូច្នេះការសួរសំណួរអាចមានការលំបាក ។

សំណួរដែលសួរដោយសហព្រះរាជអាជ្ញាទីមួយមិនបានទាញយកព័ត៌មានបានច្រើនទេពី រម៉ាំ យុន ដោយសារគាត់មានបញ្ហាទាក់ទងនឹងការយល់ដឹងសំណួរដែលចោទសួរ និងបញ្ហាភាសា ។ សណ្ឋាននៃសំណួររបស់ព្រះរាជអាជ្ញាមិនបានជួយឲ្យទទួលបានព័ត៌មានច្រើនទេ ទោះបីតុលាការបានណែនាំព្រះរាជអាជ្ញាជាច្រើនដងឲ្យសួរសំណួរឲ្យខ្លី និងច្បាស់ក៏ដោយ ។ សហព្រះរាជអាជ្ញានៅតែសួរសំណួរយ៉ាងវែង ហើយនិងលម្អិតដដែល ហើយរឹតតែធ្វើឲ្យសាក្សីកាន់តែមានការភាន់ច្រឡំច្រើនឡើង ។

ដោយងាកមករកតួនាទីរបស់គាត់ក្នុងចលនាខ្មែរក្រហមវិញ រម៉ាំ យុន បានរៀបរាប់ថា គាត់ត្រូវ បានដំឡើងជាលេខាស្រុកដោយគណៈភូមិភាគ តែគាត់មិនដឹងថានរណាជាប្រធានភូមិភាគទេ ។ គាត់បានអះ អាងទៀតថា ទោះជាគាត់មិនដែលតែងតាំងទៅជាគណៈតំបន់ក៏ដោយ តែគាត់បានធ្វើការជាមួយគណៈ តំបន់គ្រប់កម្រិតទាំងអស់ ។

ទាក់ទងទៅនឹងរចនាសម្ព័ន្ធភូមិភាគឦសាន រម៉ាំ យុន បានរៀបរាប់ថា គាត់ចាំថារចនាសម្ព័ន្ធមាន ភូមិ ឃុំ ស្រុក ហើយក្រោយមកមានតំបន់ដែលស្ថិតនៅក្រោមភូមិភាគ ។ គាត់បន្តទៀតថា មានរចនាសម្ព័ន្ធយោធាបុកងពលមួយនៅក្នុងភូមិភាគឦសាន តែគាត់មិនស្គាល់លេខរបស់កងពលនោះទេ ។ ក្រោយពីសួរសំណួរអស់ជាង៣០នាទីដោយយឺតៗ និងមិនសូវជាបានការ ចៅក្រម និល ណុន បានបញ្ឈប់សហព្រះរាជអាជ្ញាដោយសារតែអស់ម៉ោងហើយ ។ តុលាកាមិនបានទុកពេលឲ្យព្រះរាជអាជ្ញាជាតិសួរសំណួរ ដែលគាត់ក៏មានគម្រោងនិងសួរ រម៉ាំ យុន ដែរទេ ។

ក្រោយមក សហព្រះរាជអាជ្ញារង វីលៀម ស្មីត បានលើកពីបញ្ហាពេលវេលាមកនិយាយ ។ គាត់បានរំឭកទៅចៅក្រម និល ណុន ដែលបាននិយាយកាលពីថ្ងៃច័ន្ទថា តុលាការមិនដាក់កំហិតពេលវេលាដើម្បីសួរសាក្សីទេ ។ គាត់ក៏បាននិយាយដែរថា នាកិច្ចប្រជុំស្តីអំពីការរៀបចំក្នុងសវនាការដែលពេលនោះ តុលាការបានផ្តល់ពេលមួយភាគបីនៃពីរម៉ោងកន្លះទៅសហព្រះរាជអាជ្ញាដើម្បីសួរសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ហើយពេលវេលាដែលខ្លួនមានពេលនេះតិចណាស់ ។ វីលៀម ស្មីត បានស្នើទៅតុលាការឲ្យប្រាប់ភាគីទាំងអស់ពីពេលវេលាដែលខ្លួនមានសម្រាប់សួរសាក្សីនីមួយៗនៅពេលរសៀលនេះ ។

ដោយខឹងសហព្រះរាជអាជ្ញារងដែលបានបង្អាក់ដំណើរការនេះ ចៅក្រម និល ណុន បានប្រកាសថា តុលាការបានកំណត់ពេលដែលត្រូវសួរព្រោះការសួរសំណួរកាលពីម្សិលមិញ “មិនពាក់ព័ន្ធគ្នាសំណួរច្រំដែល និងមិនបានប្រើប្រាស់ពេលឲ្យត្រឹមត្រូវទេ” ។ ក្រោយមក ចៅក្រម និល ណុន បានពិគ្រោះជាមួយចៅក្រម ។ ដោយអះអាងថា “ពេលវេលាដើរលឿនណាស់មិនរង់ចាំទេ” ចៅក្រមបានស្នើទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថាតើ រម៉ាំ យុន អាចត្រឡប់មកធ្វើសក្ខីកម្មពេលក្រោយឬ

អត់ ។ ពេជ អង្គ បានឆ្លើយតបថា រម៉ាំ យុន នឹងមកម្តងទៀតបានបើសិនជាអង្គសវនាការកោះហៅគាត់ឲ្យចូលមកនៅថ្ងៃណាមួយ ។ ភ្លាមនោះ អង្គសវនាការសម្រេចផ្តល់ពេល១៥នាទីទៀតទៅសហព្រះរាជអាជ្ញា ដើម្បីបញ្ចប់សំណួរ ។

ការឆ្លើយតបទៅសហព្រះរាជអាជ្ញាទាក់ទងទៅនឹងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ រម៉ាំ យុន បានរៀបរាប់ថា គាត់ឮថា ប្រជាជនត្រូវបានជម្លៀស តែគាត់មិនបានឃើញផ្ទាល់ភ្នែកទេ ។ គាត់និយាយទៀតថា គាត់មិនឃើញមានការជម្លៀសប្រជាជនទេ ហើយគាត់ដឹងតាមតែការនិយាយពីមាត់មួយទៅមាត់មួយប៉ុណ្ណោះ ។

នៅពេលសួរអំពីការរៀបការ រម៉ាំ យុន ឆ្លើយថា មនុស្សមិនរៀបការទេ “ក្នុងសម័យ ប៉ុល ពត” ។ តែមនុស្ស “អាចស្រឡាញ់គ្នា និងរស់នៅជាមួយគ្នាដោយមិនបាច់រៀបការ” ។ តែមុនសម័យ ប៉ុល ពត ទើបមានពិធីរៀបការ ។

ដោយមិនបានទទួលព័ត៌មានច្រើនតាមចិត្តចង់ សហព្រះរាជអាជ្ញាបានបញ្ចប់សំណួររបស់ខ្លួន ។ តុលាការបានសួរទៅមេធាវីការពារក្តីថាតើមានសំណួរអ្វីដើម្បីសួរសាក្សីដែរឬអត់? ដោយដឹងថា គ្រប់ភាគីការពារក្តីទាំងអស់សុទ្ធតែមានសំណួរដើម្បីសួរទៅសាក្សី តុលាការសម្រេចថាបញ្ឈប់សាក្សីត្រឹមនេះ ហើយតុលាការនឹងកោះហៅសាក្សីរូបនេះនៅពេលក្រោយទៀត ។

## ភាពតានតឹងនៅក្នុងបន្ទប់សវនាការ

មុននឹងតុលាការសម្រាកអាហារថ្ងៃត្រង់ វីលៀម ស្មីត បានស្នើថា សហព្រះរាជអាជ្ញាគួរតែផ្តល់ពេលមួយម៉ោងកន្លះ ដើម្បីសួរសំណួរសាក្សីដែលគ្រោងនឹងចូលមកធ្វើសក្ខីកម្មនៅពេលរសៀលនេះ ដោយសារតែព្រះរាជអាជ្ញាមានភារកិច្ចនាំមុខក្នុងការសួរ ។ វីលៀម ស្មីត បានសួរទៅតុលាការឲ្យបញ្ជាក់ឲ្យច្បាស់ថា តុលាការបានអញ្ជើញសាក្សីឲ្យមកធ្វើសក្ខីកម្មនៅថ្ងៃនេះឬថ្ងៃស្អែក ។

ចៅក្រម និល ណុន បានឆ្លើយថា សាក្សីTCW៣៩៥រំពឹងថានឹងធ្វើសក្ខីកម្មនៅថ្ងៃនេះ និងពេញមួយថ្ងៃនៅថ្ងៃស្អែក និងអាចនៅថ្ងៃសុក្រផង ។ ដោយធ្វើការរំឭកទៅគ្រប់ភាគីទាំងអស់អំពីសុខភាពចាស់ជរារបស់សាក្សី និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិជ្ជាវីដេអូ ចៅក្រម និល ណុន បានជូនដំណឹងទៅគ្រប់ភាគីទាំងអស់ឲ្យចេះបទបែនតាមកាលៈទេសៈ និងត្រៀមខ្លួនជាប់ជានិច្ច “ដើម្បីធ្វើគម្រោងទីពីរ” ។

ក្រោយមក វីលៀម ស្មីត បានសួរថាតើតុលាការបានធ្វើការសម្រេចចិត្តហើយឬនៅទាក់ទងទៅនឹងសំណើដែលខ្លួនស្នើកាលពីមុន ដើម្បីអនុញ្ញាតឲ្យភាគីទាំងអស់សួរសំណួរទៅសាក្សីនាពេលរសៀលនេះ អំពីអង្គហេតុពិតនៅក្នុងបទពិរុទ្ធដែលសាក្សីបានដឹង ។

មុននឹងចៅក្រមឆ្លើយសំណួរ មេធាវីរបស់ នួន ជា ឈ្មោះ អេនឌ្រូ អៀនូហ្ស៊ី បាននិយាយកាត់ ហើយសុំឲ្យតុលាការពន្យល់ថា អ្វីជាគម្រោងទីពីរនោះ ។

ចៅក្រម ខាត់វ្រាយត៍ បានឆ្លើយថា មិនមានគម្រោងទីពីរច្បាស់លាស់ទេ តែប្រធានចៅក្រមគ្រាន់តែចង់ជម្រាបទៅគ្រប់ភាគីទាំងអស់ឲ្យរក្សានូវភាពបត់បែនតាមកាលៈទេសៈ ។ ដោយឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ចៅក្រម និល ណុន បានឆ្លើយដោយសោះកក្រោះថា «បើនៅតែមិនច្បាស់ទៀត សូមលោកទៅអានអ្វីដែលបានសរសេរនោះម្តងទៀតទៅ» ដោយដឹងថា សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងរួចហើយពីបញ្ហានេះ ។ ចៅក្រម និល ណុន បានបន្តទៀតថា «ដូចជាមានបញ្ហាច្រើនណាស់» ហើយក្រោយមកចៅក្រមបានស្នើឲ្យ រម៉ាំ យុន បន្តអង្គុយនៅក្នុងបន្ទប់សវនាការក្នុងករណី ដែលប្រព័ន្ធវីដេអូមានបញ្ហាបច្ចេកទេសដែលមិនអាចដំណើរការបាន ។ ក្រោយមកតុលាការបន្តាប់ឲ្យសម្រាកហូបអាហារថ្ងៃត្រង់ ។

## សាក្សីទីមួយរបស់ព្រះរាជអាជ្ញាឡើងធ្វើសក្ខីកម្មតាមខ្សែវីដេអូ

គ្រាន់តែតុលាការចាប់ផ្តើមដំណើរការនៅពេលរសៀលភ្លាម តុលាការបានចាប់ផ្តើមទាក់ទងជាមួយសាក្សីទីមួយរបស់ព្រះរាជអាជ្ញាឈ្មោះ ឡុង នរិន្ទ តាមរយៈខ្សែវីដេអូ ។ ឡុង នរិន្ទ បានឃើញតាមកញ្ចក់ទូរទស្សន៍រហូតនៅក្នុងបន្ទប់ ដោយគាត់អង្គុយនៅលើកៅអីមួយក្នុងផ្ទះរបស់គាត់ក្បែរបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជនាញម្នាក់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទោះបីជារូបភាពរបស់ប្រព័ន្ធវីដេអូ មិនមានការរអាក់រអួលអ្វីក៏ដោយ តែតុលាការជួបប្រទះនូវការលំបាកខ្លះទាក់ទងទៅនឹងប្រព័ន្ធសំឡេងអមដោយសំឡេងមកពីខាងក្រោយផង ដែលធ្វើឲ្យសាក្សីមិនអាចឮសំណួរច្បាស់ ។

បញ្ហានេះធ្វើឲ្យការចោទសួរដំណើរការទៅយឺតៗ ដែលបង្កឲ្យមានការរំខានដល់ចៅក្រមផង និងភាគីទាំងអស់ ព្រមទាំងអ្នកចូលរួមតាមដានផង ។ ចៅក្រម និល ណុន បានចាប់ផ្តើមដោយបញ្ជាក់សាឡើងវិញអំពីស្ថានភាពរបស់សាក្សី និងបញ្ហាមួយចំនួនទៀត ដែលអាចកើតឡើងនៅអំឡុងពេលនៃការចោទសួរ ។ ការបកប្រែសម្តីរបស់ ឡុង នរិន្ទ នឹងធ្វើឡើងមួយវគ្គៗ មិនមែនបកប្រែស្របពេលជាមួយគ្នាទេ ហើយចៅក្រមបានណែនាំឲ្យមានការទុកពេលសម្រាប់សួរ និងឆ្លើយ និងបកប្រែមុននឹងសួរបន្តទៀត ។ ពេលដែលបុគ្គលិកកំពុងតែភ្ជាប់ខ្សែវីដេអូ ចៅក្រម និល ណុន បាននិយាយដដែលៗថា «លោក ឡុង នរិន្ទ ឮខ្ញុំនិយាយទេ?» ក្រោយពីបណ្តាញរៀបចំត្រឹមត្រូវហើយ ការសួរសំណួរចាប់ផ្តើមឡើង ។ ដូចគ្នានឹងដើមបណ្តឹងរដ្ឋប្បវេណីដែរ សក្ខីកម្មរបស់ ឡុង នរិន្ទ ចាប់ផ្តើមឡើងដោយការសួរពីប្រវត្តិ ដែលពាក្យពេចន៍ជាច្រើន ត្រូវបាននិយាយសាឡើងវិញដោយបុគ្គលិកដែលអង្គុយជិត

គាត់។ ឡុង នរិន្ទ បានរៀបរាប់ថា គាត់កើតក្នុងឆ្នាំ១៩៧៨ ហើយសព្វថ្ងៃគាត់រស់នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ គាត់និយាយថា សព្វថ្ងៃគាត់ជាកសិករ "ខ្ញុំគ្រាន់តែជាកសិករប៉ុណ្ណោះ"។ គាត់រៀបការនិងមានកូនប្រាំនាក់។

ក្រោយមក ចៅក្រម និល ណុន បានឲ្យ ឡុង នរិន្ទ បញ្ជាក់ឲ្យច្បាស់ថាតើគាត់បានជាប់សាច់ឈាមជាមួយភាគីដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ ហើយថាគាត់បានស្បថឬក៏អត់ ឡុង នរិន្ទ បានឆ្លើយថា គាត់មិនជាប់សាច់ញាតិជាមួយភាគីដើមបណ្តឹងរដ្ឋប្បវេណីទេ ហើយក៏បានស្បថរួចហើយដែរ។ ក្រោយមក ចៅក្រមបានជូនដំណឹងទៅ ឡុង នរិន្ទ អំពីសិទ្ធិរបស់គាត់ក្នុងនាមជាសាក្សី រួមមានសិទ្ធិក្នុងការមិនឆ្លើយតបនឹងសំណួរ និងសិទ្ធិក្នុងការមិនដាក់បន្ទុកលើខ្លួនឯង។

ចៅក្រមសួរទៅ ឡុង នរិន្ទ ម្តងទៀតថាតើគាត់យល់ពីសិទ្ធិនេះទេ គាត់បានឆ្លើយថា "ខ្ញុំសុំទៅបន្ទប់ទឹកមួយភ្លែត"។ ចៅក្រមអនុញ្ញាត។

ពេលកំពុងរង់ចាំ អាង ឧត្តម មេធាវីរបស់ អៀង សារី បានស្នើឲ្យតុលាការសួរឲ្យទៅសាក្សីម្តងទៀតថា គាត់បានស្បថហើយឬនៅ។ អាង ឧត្តម បាននិយាយថា ឡុង នរិន្ទ ហាក់បីដូចជាភាន់ច្រឡំ និងអាចគិតថា ប្រធានចៅក្រមបានសួរថា តើសាក្សីរូបនេះមានបានទទួលសំបុត្រពីតុលាការដែរឬអត់។ វីលៀម ស្មីត ក៏បានឆក់ឱកាសនេះស្នើទៅតុលាការឲ្យផ្តល់ការពន្យារពេលដល់ក្រុមព្រះរាជអាជ្ញាដើម្បីសួរសំណួរនៅពេលរសៀលវិញ ដោយសារតែការបកប្រែមួយវគ្គៗត្រូវស៊ីពេលច្រើន។ វីលៀម ស្មីត ក៏បានស្នើដែរថា ខ្លួនរង់ចាំមើលសិនថាតើត្រូវចំណាយពេលប៉ុនណាទៀតដើម្បីសួរទៅសាក្សីមួយនេះនៅថ្ងៃព្រហស្បតិ៍។ ក្រោយពីចប់កិច្ចការអស់ហើយ តុលាការបានរង់ចាំ ឡុង នរិន្ទ ចេញពីបន្ទប់ទឹកមកវិញ។ ពេលដែល ឡុង នរិន្ទ មកដល់ ចៅក្រម និល ណុន បានរៀបរាប់ទៀតថា សាក្សីក៏មានសិទ្ធិទៅបន្ទប់ទឹក គ្រប់ពេលវេលាទាំងអស់ស្រេចតែចិត្តចង់ ដោយសារបញ្ហាសុខភាព។ ចៅក្រមបានសួរទៅ ឡុង នរិន្ទ ម្តងទៀតថា បានស្បថហើយឬនៅ ហើយសាក្សីរូបនេះបាននិយាយថា គាត់ទើបតែស្បថហើយថ្មីៗនេះ។

បន្ទាប់មក សហព្រះរាជអាជ្ញានាំមុខសួរសំណួរទៅកាន់សាក្សី តែត្រូវរំខានដោយសំឡេងមកពីខាងក្រោយតាមរយៈប្រព័ន្ធបន្លឺសំឡេង។ មួយសន្ទុះក្រោយមក ចៅក្រម និល ណុន បានរៀបរាប់ថា មានពិធីរៀបអាពាហ៍ពិពាហ៍មួយនៅជិតផ្ទះរបស់សាក្សីដែលធ្វើឲ្យមានសំឡេងចេញតាមឧបករណ៍បន្លឺសំឡេង។ ក្រោយមក បុគ្គលិករបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានចេញទៅប្រាប់ម្ចាស់ដើមការឲ្យបន្ថយសំឡេង ហើយក្រោយមកសំឡេងបានថយចុះមែន ហើយសហព្រះរាជអាជ្ញាចាប់ផ្តើមសួរសំណួរតទៅទៀត។

ទោះជាមានសំឡេងរំខាននៅពីក្រោយក៏ដោយ តុលាការបានព្យាយាមនិយាយទៅគាត់ជាច្រើនដង ទើបក្រោយមក ឡុង នរិន្ទ ទទួលស្គាល់ថា មានអ្នកកំពុងនិយាយមកកាន់គាត់។ នៅពេលដែលសាក្សីរូបនេះឆ្លើយថា គាត់អាចឮសំណួរសហព្រះរាជអាជ្ញាបានស្នើទៅសាក្សីដើម្បីឲ្យគាត់រៀបរាប់ពីកម្រិតវប្បធម៌។ សំណួរនេះមិនមានចម្លើយពី ឡុង នរិន្ទ ទេ។ សហព្រះរាជអាជ្ញាបានសួរទៅគាត់ម្តងហើយម្តងទៀត តែនៅតែមិនដឹងថាសាក្សីនេះបានឮគាត់ឬក៏អត់ទេ។ ទីបញ្ចប់ ចៅក្រម និល ណុន បានសួរទៅបុគ្គលិករបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញថាឮគាត់សួរដែរឬអត់។ បុគ្គលិកនោះបានឆ្លើយថា គាត់ឮសំណួរ។ ដូច្នេះព្រះរាជអាជ្ញាក៏ចាប់ផ្តើមសួរបន្តទៀត។

ក្រោយពីផ្អាកនៅស្ងៀមមួយសន្ទុះ ដែលពេលនោះបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញសម្លឹងមើលមុខរបស់ ឡុង នរិន្ទ តែមិននិយាយស្តីអ្វីទេនោះ ឡុង នរិន្ទ បានឆ្លើយនិងសំណួរដោយនិយាយថា កាលពីគាត់នៅក្មេង គាត់ទៅរៀននៅប្រទេសឆេកូស្លូវ៉ាគី ពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៧១ ដើម្បីរៀនពីកាយសម្ព័ន្ធ។ ក្រោយមកក្នុងឆ្នាំ១៩៧១ គាត់បានចាកចេញពីទីក្រុងប្រ៉ាក ទៅកាន់ទីក្រុងប៉េកាំង ព្រោះសម្តេច សីហនុ បានអំពាវនាវឲ្យប្រជាជនកម្ពុជាដែលរស់នៅក្រៅប្រទេសទាំងអស់ចូលតស៊ូប្រឆាំងនឹងចលនាដែលហៅថា «ធ្វើការដើម្បីប្រទេសជាតិ»។ ឡុង នរិន្ទ បានបន្តនៅទីក្រុងប៉េកាំងអស់រយៈពេលប្រាំមួយខែរហូតដល់រដ្ឋាភិបាលរួបរួមជាតិ ដែលជារដ្ឋាភិបាលនិរទេសក្រោយរដ្ឋប្រហារ លន់ នល់ អញ្ជើញគាត់ ទើបគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ។

ក្រោយមក សហព្រះរាជអាជ្ញាបានសួរពីតួនាទីរបស់សាក្សីកាលពីនៅទីក្រុងប៉េកាំង។ ពេលនោះ ឡុង នរិន្ទ មិនបានឆ្លើយទេ តែគាត់នៅតែសម្លឹងមើលកាម៉េរ៉ាវីដេអូជានិច្ចដោយមិនផ្តល់សញ្ញាណាមួយថា គាត់បានឮសំណួរទេ។ ចៅក្រម និល ណុន បានសួរទៅបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញថា ឮសំណួរឬអត់? ហើយបុគ្គលិកនោះឆ្លើយថា ឮ។ ចៅក្រមក៏បានប្រាប់ទៅបុគ្គលិកនោះឲ្យអានសំណួរឡើងវិញទៅសាក្សីរូបនោះ។

ក្រោយពីបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញអានសំណួរសាឡើងវិញរួចមក ឡុង នរិន្ទ បានឆ្លើយថា គាត់ធ្វើការនៅក្រសួងការបរទេស ពេលដែលគាត់នៅប្រទេសចិន។ នៅក្នុងមុខតំណែងនេះ គាត់មានភារកិច្ចសរសេរលិខិតដើម្បីបង្កើតចំណងការទូតជាមួយក្រុមប្រទេសផ្សេងៗទៀត។

ឡុង នរិន្ទ បានរៀបរាប់ថា ពេលដែលគាត់នៅទីក្រុងប៉េកាំង គាត់បានជួបជាមួយ អៀង សារី នៅពេលដែល អៀង សារី ត្រឡប់មកពីប្រទេសបារាំងវិញ។ ឡុង នរិន្ទ បានអះអាងទៀតថា ពេលនៅទីក្រុងប៉េកាំង អៀង សារី គឺជាបេសកជនពិសេសទទួលបន្ទុកខាងកិច្ចការបរទេសសម្រាប់រដ្ឋាភិបាលកម្ពុជា។ ឡុង នរិន្ទ រៀបរាប់ថា គាត់ធ្លាប់ជួប អៀង សារី ជាច្រើនមុននោះទៅទៀត តែ

ពេលដែលគាត់រស់នៅប្រទេសឆេកូស្លូវ៉ាគី គាត់មិនមានទំនាក់ទំនងកិច្ចការណាមួយជាមួយ អៀង សារី ទេ ។

គាត់បានចូលបក្សកុម្មុយនីស្តកម្ពុជា ពេលដែលប្រទេស«មានសង្គ្រាមប្រឆាំងនឹងអាមេរិក» គាត់បានបញ្ជាក់ទៀតថា អ្នកដែលធ្វើការនៅក្នុងក្រសួងការបរទេសទាំងអស់ ចូលបក្សដោយស្ម័គ្រចិត្ត «យើងចូលបក្សដោយសតិសម្បជញ្ញៈរបស់យើង ។ យើងចូលបក្ស ព្រោះនៅពេលនោះប្រទេសកម្ពុជាត្រូវបានឈ្លានពានពីប្រទេសផ្សេង» ។ ក្រោយពីរស់នៅទីក្រុងប៉េកាំងអស់រយៈពេលប្រាំមួយខែ ឡុង នរិន្ទ បានត្រឡប់មកប្រទេសកម្ពុជាវិញ ។ គាត់បានធ្វើដំណើរតាមទីក្រុងហាណូយ ដែលពេលនោះគាត់ជួបជាមួយ អៀង ធីរិទ្ធ ដែលជារដ្ឋមន្ត្រីសង្គមកិច្ចនៃរបបខ្មែរក្រហមហើយជាប្រពន្ធរបស់ អៀង សារី ។ អៀង ធីរិទ្ធ ទទួលខុសត្រូវខាងស្ថានីយវិទ្យុទាក់ទងនៃរណសិរ្សប្រជុំបង្រួមជាតិកម្ពុជា ដែលផ្សាយចេញពីទីក្រុងហាណូយ ។ ឡុង នរិន្ទ បានរៀបរាប់ថា កាលនោះ អៀង សារី បានណែនាំឲ្យគាត់ចូលធ្វើការនៅស្ថានីយវិទ្យុដើម្បី«បម្រើចលនាតស៊ូ» ដូច្នេះគាត់ក៏សម្រេចចិត្តថា នឹងធ្វើការនៅស្ថានីយវិទ្យុនៅទីក្រុងហាណូយនេះ ហើយគាត់បានធ្វើការនៅទីនោះអស់រយៈពេលប្រាំមួយខែទៀត ។

សាក្សីរូបនេះក៏បានរៀបរាប់ទៀតថា គោលបំណងរបស់ស្ថានីយវិទ្យុនេះ គឺដើម្បីផ្សព្វផ្សាយពីចលនាតស៊ូ និងអប់រំឃោសនាទៅប្រជាជនកម្ពុជាដែលធ្វើការនៅបរទេសឲ្យត្រឡប់មកមាតុភូមិវិញ ។ ឡុង នរិន្ទ ធ្លាប់ធ្វើការជាអ្នកបកប្រែ និងជាអ្នកសរសេរអក្សរកូដនៅទីក្រុងហាណូយ ដោយបកប្រែអក្សរខ្មែរទៅជាភាសាឡាតាំង និងផ្សព្វផ្សាយតាមវិទ្យុ ។ ឡុង នរិន្ទ ក៏បានបញ្ជាក់ដែរថា គាត់ទទួលបន្ទុកខាងផ្សព្វផ្សាយកម្មវិធីអប់រំឃោសនាទៅប្រជាជនខ្មែរដែលរស់នៅទីក្រុងហាណូយ ។

ពេលនិយាយដល់ចំណុចនេះ ឡុង នរិន្ទ សុំទៅបន្ទប់ទឹកម្តងទៀត ហើយតុលាការក៏អនុញ្ញាតឲ្យសម្រាកនៅពេលរសៀល ។

បន្ទាប់ពីសម្រាករួច តុលាការបានសុំឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីពីររូបគឺ ក្លាន ហ៊ីត និង រម៉ាំ យុន ត្រឡប់ទៅគេហដ្ឋានវិញ ។ តុលាការក៏បានជូនដំណឹងទៅភាគីទាំងអស់ថា ក្លាន ហ៊ីត និង រម៉ាំ យុន និងត្រូវអញ្ជើញឲ្យមកកាន់តុលាការម្តងទៀតនៅថ្ងៃក្រោយ ដែលប្រហែលជាខែក្រោយ ។

មុននឹងចាប់ផ្តើមសួរសំណួរតទៅទៀត សហព្រះរាជអាជ្ញាបានសួរទៅតុលាការថា មានបានអនុញ្ញាតឲ្យមានការចោទសួរទៅសាក្សី ឡុង នរិន្ទ ទៀតឬអត់នៅព្រឹកស្អែក ហើយគាត់ក៏បានបញ្ជាក់ពីការរអាក់រអួលនៃការប្រើប្រាស់ប្រព័ន្ធវីដេអូ ។ ចៅក្រម និល ណុន មិនបានឆ្លើយទេ តែបានងក់ក្បាលដែលមានន័យ ឡុង នរិន្ទ និងមកធ្វើសក្ខីកម្មនៅថ្ងៃស្អែកទៀត ។

ក្រោយមក   សហព្រះរាជអាជ្ញាបានចាប់ផ្តើមសួរទៅសាក្សីបន្តទៀតនូវសំណួរជាច្រើនទាក់ទងទៅនឹងគោលបំណងរបស់ស្ថានីយវិទ្យុនៅទីក្រុងហាណូយ ដែលសាក្សីរូបនេះធ្វើការក្រោយពីចាកចេញពីទីក្រុងប៉េកាំង ។ ឡុង និរិន្ទ បានឆ្លើយថា សេចក្តីណែនាំសម្រាប់ស្ថានីយវិទ្យុនោះ ព្រមទាំងសម្ភារៈនានាយកមកពីប្រទេសកម្ពុជា ។ អត្ថបទដែលត្រូវផ្សព្វផ្សាយសរសេរនៅកម្ពុជាបញ្ជូនទៅទីក្រុងហាណូយ រួចផ្សព្វផ្សាយទៅប្រទេសកម្ពុជាវិញ និងប្រទេសផ្សេងៗទៀត ។

សហព្រះរាជអាជ្ញាបានសួរថា តើពេលណាទើបគាត់ត្រឡប់មកប្រទេសកម្ពុជា ឡុង និរិន្ទ បានឆ្លើយថា ប្រាំមួយខែក្រោយពីរស់នៅទីក្រុងហាណូយ គាត់បានត្រឡប់មកប្រទេសកម្ពុជាវិញ ដោយមកធ្វើការនៅមន្ទីរប-១ ឬក្រសួងការបរទេស ។ ពេលខ្លះ «ពេលដែលប្រទេសមានសន្តិភាពហើយ» គាត់ក៏បានទៅធ្វើការនៅខេត្តស្ទឹងត្រែងដែរ គឺទីតាំងចំនួនពីរនៅមន្ទីរប-២០ និងប-១៥ ។ ទីតាំងទាំងពីរនេះ គឺជាកន្លែងធ្វើកសិកម្ម និងដំណាំផ្សេងៗទៀត ។

ក្រោយពីផ្តល់ព័ត៌មាននេះរួចមក សាក្សីសុំទៅបន្ទប់ទឹកម្តងទៀត ។ ពេលដែលអង្គសវនាការចាប់ផ្តើម ចៅក្រម និល ណុន បន្ទោសបុគ្គលិករបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដោយ «អង្គុយធ្មឹង» មិនជួយសម្របសម្រួល ឡុង និរិន្ទ អ៊ីសោះពេលដែលគាត់មិនព្រសំណួរ ។ ចៅក្រមបានស្នើថា បុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញគួរតែជួយសាក្សីឲ្យមានភាពរស់រវើកឡើង ដើម្បីបន្តសក្ខីកម្មនេះទៅមុខឲ្យបានលឿន ។ ក្រោយមក សហព្រះរាជអាជ្ញាបានសួរទៅសាក្សីទៀតថា មានដែលធ្វើការនៅខេត្តព្រះវិហារឬអត់ ។ សាក្សីរូបនេះបានឆ្លើយថា មុននឹងភ្នំពេញត្រូវបានរំដោះ គាត់ត្រូវបានបញ្ជូនទៅធ្វើការនៅខេត្តព្រះវិហារ ដើម្បី«សិក្សាពីស្ថានភាពប្រជាជន» ហើយគាត់បានរាយការណ៍ថា អ្នកដែលប្រាប់គាត់ឲ្យធ្វើកិច្ចការណាមួយនោះគឺ នួន ជា និង ខៀវ សំផន ដែល ឡុង និរិន្ទ ស្គាល់ថា ជាមេដឹកនាំដំបូងគេនៅមន្ទីរប-២០ ជាកន្លែងដែល នួន ជា និង ខៀវ សំផន ប្រាប់ ឡុង និរិន្ទ ថាអ៊ីដែលត្រូវធ្វើនិងកន្លែងដែលត្រូវទៅ ។

ពេលដែលគាត់ទៅខេត្តព្រះវិហារ ឡុង និរិន្ទ ត្រូវបានប្រាប់ថា មិនឲ្យត្រឡប់មកទីក្រុងភ្នំពេញវិញទេ ។ គាត់ត្រូវនៅទីនោះរហូតទាល់តែមានការជូនដំណឹងពីមេដឹកនាំខ្មែរក្រហម ។ ក្នុងខែមេសា ឆ្នាំ ១៩៧៥ ប្រធានភូមិដែលគាត់រស់នៅបានជូនទូរលេខមួយមកគាត់ ហើយទូរលេខនោះបានបញ្ជាឲ្យ ឡុង និរិន្ទ ធ្វើដំណើរទៅទីក្រុងភ្នំពេញ ។

ពេលដែលគាត់មកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ គាត់ឃើញមនុស្សយ៉ាងច្រើនកកកុញធ្វើដំណើរចេញពីទីក្រុងភ្នំពេញដែលគាត់មិនដឹងថា អ្នកនោះទៅណាទេ ។ គាត់បាននិយាយថា គាត់មិនដឹងថាទីក្រុងភ្នំពេញត្រូវបានជម្លៀសទេ ។ ដោយឆ្លើយសំណួរអំពីតួនាទីរបស់គាត់ពី

ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡុង នរិន្ទ បានឆ្លើយថា គាត់ធ្វើការនៅមន្ទីរប-១ ឬក្រសួងការបរទេសទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ។ ពេលនោះគាត់ "វាយទូរលេខ" តែគាត់មិនចាំថាទូរលេខអ្វីខ្លះទេ ។ ក្នុងអាការៈខឹង ឡុង នរិន្ទ បាននិយាយថា "វាកន្លងទៅ៣០ឆ្នាំហើយ ធ្វើម៉េចនឹងខ្ញុំចាំរឿងរ៉ាវទាំងអស់នោះទៅ?" ឡុង នរិន្ទ ក៏បានរៀបរាប់ដែរថា គាត់ក៏រៀបចំលិខិតឆ្លងដែនសម្រាប់អ្នកដែលទៅធ្វើការនៅបរទេសដែរ ។ តែគាត់មិនមានភារៈចាត់ចែងខាងដំណើរទស្សនកិច្ចរបស់ភ្ញៀវបរទេសមកកម្ពុជាទេ ។ សាក្សីរូបនេះនិយាយទៀតថា គាត់មិនចាំឈ្មោះនរណាមួយធ្វើការនៅក្រសួងការបរទេសដែលបាត់ខ្លួន ឬត្រូវបានចាប់ខ្លួននោះទេ ។

ក្រោយមក សហព្រះរាជអាជ្ញាបានសួរទៅ ឡុង នរិន្ទ ថា គាត់មានដែលត្រូវខ្មែរក្រហមប្រាប់ឲ្យធ្វើប្រវត្តិរូបដែរឬអត់ ពេលដែលគាត់ធ្វើការនៅក្រសួងការបរទេសនោះ ។ គាត់បានឆ្លើយថា គាត់ត្រូវបានស្នើឲ្យធ្វើប្រវត្តិរូបដែរ ហើយគាត់បានចំណាយពេលមួយឆ្នាំដើម្បីធ្វើប្រវត្តិរូបដ៏លម្អិតនោះ ។ ខ្មែរក្រហមមិនដែលប្រាប់គាត់ថាធ្វើប្រវត្តិរូបនោះដើម្បីអ្វីទេ តែគាត់បានប្រាប់ថា អៀង សារី បានសួរគាត់ដោយផ្ទាល់ថា តើគាត់ចូល សេ.អ៊ី.អា. ពីអង្កាល តែពេលនោះគាត់មិនបានសារភាពទៅ អៀង សារី ថាគាត់ជិតស្និទ្ធជាមួយ ថាច់ ជា ដែល អៀង សារី "ដឹងថា ជា សេ.អ៊ី.អា." នោះទេ ។

ក្រោយពីសួរពីសំណួរជាច្រើនទាក់ទងនឹងប្រវត្តិរូបរួចមក សហព្រះរាជអាជ្ញាបានជូនដំណឹងទៅតុលាការថា សហព្រះរាជអាជ្ញាមានឯកសារមួយដែលខ្លួនជឿថា ជាប្រវត្តិរូបរបស់ ឡុង នរិន្ទ ។ ដោយបញ្ជាក់ថា សហព្រះរាជអាជ្ញាចង់បង្ហាញឯកសារនេះ ខ្លួនបានស្នើទៅតុលាការឲ្យជួយកិច្ចការមួយចំនួនដើម្បីបញ្ចាំង ។ ដោយអាការៈហត់នឿយពេញមួយថ្ងៃ ចៅក្រម និល ណុន បានឆ្លើយតបថា ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយសម្រាប់ថ្ងៃនេះ ។ ឯកសារទាក់ទងនឹង ឡុង នរិន្ទ នឹងបង្ហាញជូននៅថ្ងៃស្អែក ។

**-ចប់-**